ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

លេខៈ ២៤៧ /១៥-០៣-២០១១

សាលដីកា

លេខ ០៣ក្រាវត/៣-១-២០១២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខៈ០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៣-០១-២០១២ ដោយមានសមាសភាពដូចតទៅ :

**គ្រួមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខៈ២៤៧ ចុះថ្ងៃទី ១៥-០៣-២០១១ រវាង :

-ជនជាប់ចោទឈ្មោះ [redacted] សុខលាភ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរសន្តិសុខឯកជន កើតនៅខេត្តក្រចេះ ទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះស្រី យៅ វី ទោសពីមុនមាន។ ចាប់ខ្លួនថ្ងៃទី ២៣-១១-២០០៨. ឃុំខ្លួនថ្ងៃទី ២៧-១១-២០០៨ (ម១)មេធាវី [redacted] តារា

ត្រូវចោទពីបទ :ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥-០៣-២០០៩ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនរងគ្រោះឈ្មោះ [redacted] សូខៀន ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះគ្មានលេខ [redacted]។/៤





Scanned with CamScanner

## ឯរឿងហេតុមានដូចតទៅ:

កាលពីថ្ងៃទី១៥-១១-២០០៨ មានករណីប្លន់ដែលបង្កឡើងដោយជនល្មើសមានគ្នា០៨នាក់ទៅ០៩នាក់ ប្រដាប់ដោយអាវុធខ្លីមួយដើម និងពូថៅគ្រប់ដៃបានប្លន់យកម៉ូតូពីជនរងគ្រោះឈ្មោះ ជ័យ សូឡៃនទៅលើដងផ្លូវលេខ២៨៨កែង៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញបានសម្រេច រួចគេខ្លួនបាត់អស់រហូតដល់ថ្ងៃទី២៣-១១-២០០៨ វេលាម៉ោង១៣ :៣០នាទី ជនរងគ្រោះបានប្រទះឃើញម៉ូតូរបស់ខ្លួននៅខាងក្រោយនាគពន្ធ័ ហើយបានប្តឹងសមត្ថកិច្ចៗបានចុះទៅដល់ហើយឃាត់ខ្លួនឈ្មោះហែម សុខលាភ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៦៩៩កប៥ ចុះថ្ងៃទី ២៤-០៨-២០០៩ របស់សាលាដំបូងរាជធានី ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះ [redacted] សុខលាភ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៥( ប្រាំ) ឆ្នាំ ពីបទប្លន់( ម៉ូតូ) ប្រព្រឹត្តនៅបណ្តោយផ្លូវលេខ២៨៨ កែង៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥-១១-២០០៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ០៣-០៨-២០០៩ និងប្រកាសជាសាធារណៈថ្ងៃទី២៤-០៨-២០០៩ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខជនរងគ្រោះ សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ៤២៣ ចុះថ្ងៃទី២៨-០៨-២០០៩របស់ឈ្មោះ [redacted] សុខលាភ សុំប្តឹង ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៦៩៩កប៥ "ជ" ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ ត្រង់ចំណុចសេចក្តីសម្រេចសាលក្រមទាំងមូល ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី ៣១-០៥-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ( អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សុខលាភ បានឆ្លើយបញ្ជាក់ថា ខ្លួនប្តឹងឧទ្ធរណ៍មកដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ។ ខ្លួនមិនដែលស្គាល់ក្មេង៧-៨នាក់ដែលយកម៉ូតូមកនោះទេ ពួកគេមកជាមួយឈ្មោះលី ហើយ ខ្លួនជាប់ពាក់ពន្ធ័រឿងឱ្យមិត្តភក្រ័ខ្ញុំអត្តសញ្ញាណយកម៉ូតូទៅបញ្ចាំ ។មិត្តភក្រ័ខ្លួនឈ្មោះអាខ្មុយវាបញ្ចាំម៉ូតូបានលុយ១០០ដុល្លា វាឱ្យខ្លួន១០ដុល្លា ។ ចម្លើយនៅសមត្ថកិច្ចខ្លួនទទួលស្គាល់ ហើយខ្លួន ធ្លាប់ប្រាប់ពីផ្ទះ ឈ្មោះខ្មុយ និងអាតឿដល់សមត្ថកិច្ចហើយ ។ សំណូមពរសុំបន្ធូរបន្ថយទោស ព្រោះខ្លួនជាប់ពន្ធនាគារជាង៣ឆ្នាំ បានធ្វើការ កែប្រែ ខ្លួន បានល្អហើយ ។

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន : ជនជាប់ចោទឆ្លើយសារភាពស៊ីសង្វាក់ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុំទុកសិទ្ធិដល់ក្រុមប្រឹក្សាពិចារណាសម្រេច ។

មេធាវីផ្តល់សេចក្តីសន្និដ្ឋាន : អង្គហេតុនៃរឿងមានអំពើប្លន់ តែមិនទាក់ទិនដល់កូនក្តីខ្លួនទេ ហើយចម្លើយជនរងគ្រោះក៏ថា កូនក្តីខ្លួនមិនបានប្រព្រឹត្តទេ ។ សុំក្រុមប្រឹក្សាចោទពីបទ ទទួលផលចោរកម្មដោយសុំទោសព្យួរ តាមមាត្រា ១០៧នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ ។

## យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៨-០៨-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខលាភ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៦៩ក្រប៤ ចុះថ្ងៃទី២៤-០៨-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដី សម្រេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធីថា ខ្លួនពុំបានចូលរួមប្លន់ម៉ូតូទេ ប៉ុន្តែខ្លួនបានជួបឈ្មោះ លី និងឈ្មោះ ខ្មុយ ហើយឈ្មោះ ខ្មុយ បានឱ្យខ្លួនដាក់អត្តសញ្ញាណបណ្ណ័ដើម្បីបញ្ចាំម៉ូតូមួយគ្រឿងដែលជារបស់បងប្អូនគេ ដោយទទួលបានប្រាក់បញ្ចាំចំនួន១០០ដុល្លា ហើយគេឱ្យខ្លួន១០ដុល្លា ។ ឈ្មោះ លី បានឱ្យខ្លួនរកម៉ូយទិញម៉ូតូនោះ ។ ពេលលក់រួច ខ្លួនបានប្រាប់អ្នកទិញឱ្យដោះស្លាកលេខចេញតាមការប្រាប់របស់ឈ្មោះ លី និង ខ្មុយ ប៉ុន្តែអ្នកទិញមិនបានដោះចេញ ។ តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅចៅក្រមស៊ើបសួរ បានអះអាងថា ឈ្មោះ ហែម សុខលាភ មិនមែនជាអ្នកចូលរួមប្លន់ទេ ។

៣-តាមឯកសារក្នុងសំណុំរឿង និងតាមចម្លើយរបស់ជនជាប់ចោទ អាចកំណត់បានថា ជនជាប់ចោទធ្វើជាអន្តរការីក្នុងការដាក់បញ្ចាំ និងលក់ម៉ូតូ ដោយដឹងថារបស់នោះបានមកពីបទល្មើស ដែលជាបទល្មើសទទួលផលចោរកម្ម ដូចដែលតំណាងអយ្យការបានសន្និដ្ឋាននៅក្នុងដីកាសន្និដ្ឋានស្ថាពរថា ជាបទទទួលផលចោរកម្មដែរ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ៦៩ក្រប៤ ចុះថ្ងៃទី២៤-០៨-២០០៩របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចដូចបានសំអាងហេតុនៅក្នុងចំណុចទី៣ខាងលើ គប្បីកែតម្រូវឡើងវិញ ។

## ទិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨-០៨-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខលាភ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] សុខលាភ ពីបទប្លន់ តាមមាត្រា៦នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជាបទទទួលផលចោរកម្ម តាមមាត្រា៣៩៩ និងមាត្រា៤០០នៃក្រមព្រហ្មទណ្ឌ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៩ក្រប៤ ចុះថ្ងៃទី២៤-០៨-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី១នៃសេចក្ដីសម្រេចត្រង់ " ផ្ដន្ទាទោសឈ្មោះ ហែម សុខលាភ ដាក់ពន្ធនាគារកំណត់៥ឆ្នាំ" ត្រូវកែប្រែជា " *ផ្ដន្ទាទោសឈ្មោះ [redacted] សុខលាភ ដាក់ពន្ធនាគារកំណត់៣ឆ្នាំ៣ខែ (បីឆ្នាំបីខែ) ពីបទទទួលផលចោរកម្ម តាមមាត្រា៣៩៩ និងមាត្រា៤០០នៃក្រមព្រហ្មទណ្ឌ* " ។ ចំណុចដទៃទៀតនៃសាលក្រមនៅរក្សាទុកជាបានការដដែល ។



Scanned with CamScanner

៤-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្ត សាលដីកានេះ អោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា : [redacted] | ហត្ថលេខា : [redacted] | ហត្ថលេខា: [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]



Scanned with CamScanner